# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ០៥៧ MISTI / ២០២១

## ប្រកាស
## ស្តីពី
## នីតិវិធី និងបែបបទនៃការស្នើសុំនាំចូលឧបករណ៍មាត្រាសាស្ត្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញប្រកាសអន្តរក្រសួងលេខ ៥៥៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលដៅកំណត់ យន្តការ និងវិធានគ្រប់គ្រងការនាំចូលឧបករណ៍មាត្រាសាស្ត្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ .-**

ប្រកាសនេះមានគោលបំណង ៖



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- ធានាឱ្យការធ្វើពាណិជ្ជកម្ម សេវាកម្ម មានភាពយុត្តិធម៌ និងត្រឹមត្រូវ
- ជំរុញឱ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ស្របតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់
- ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់
- ធ្វើឱ្យមានជំនឿចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីធានាសុខភាព សុវត្ថិភាព និងបរិស្ថាន។

**ប្រការ៣ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើបុគ្គលដែលនាំចូលឧបករណ៍មាត្រាសាស្ត្រ សម្រាប់សកម្មភាព ពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម អាជីវកម្ម និង/ឬ វិស័យផ្សេងទៀត ដោយអនុលោមតាមច្បាប់ ស្តីពីមាត្រាសាស្ត្រ នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ._**

វាក្យស័ព្ទសំខាន់ៗ ប្រើសម្រាប់ក្នុងប្រកាសនេះ មានដូចតទៅ៖

**ឧបករណ៍មាត្រាសាស្ត្រ** សំដៅដល់ ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបម្រើឱ្យវិស័យមាត្រាសាស្ត្រ។

**ពាណិជ្ជកម្ម** សំដៅដល់ ទំនាក់ទំនង ឬកិច្ចសន្យា កិច្ចព្រមព្រៀង ការលក់ ការទិញ យោងតាមមាត្រា១៩ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ និងរាប់បញ្ចូលទាំងការវេចខ្ចប់ទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**អ្នកស្នើសុំ** សំដៅដល់ បុគ្គលដែលចុះហត្ថលេខាលើពាក្យស្នើសុំ។

**អ្នកនាំចូល** សំដៅដល់ បុគ្គលដែលបានអនុញ្ញាតឱ្យនាំចូលនូវឧបករណ៍មាត្រាសាស្ត្រ។

**បុគ្គល** សំដៅដល់ នីតិបុគ្គល ឬ រូបវន្តបុគ្គល។

**ពាក្យស្នើសុំ** សំដៅដល់ ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ជាសំណើផ្លូវការដោយលាយលក្ខណ៍អក្សររបស់អ្នកស្នើសុំ ដើម្បីទទួលបាននូវសិទ្ធិលើការនាំចូលឧបករណ៍មាត្រាសាស្ត្រ ដូចមានទម្រង់ដែលកំណត់ក្នុងប្រកាសនេះ។

**លិខិតអនុញ្ញាត** សំដៅដល់ លិខិតគតិយុត្តដែលអនុញ្ញាតឱ្យបុគ្គលដែលនាំចូល ឬ មានបំណងនាំចូលឧបករណ៍មាត្រាសាស្ត្រ ជាលាយលក្ខណ៍អក្សរដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ឯកសារតម្រូវ** សំដៅដល់ ឯកសារពាក់ព័ន្ធនានាដែលតម្រូវឱ្យមានភាពអនុលោមជាមួយលក្ខខណ្ឌដែលបានកំណត់ក្នុងប្រកាសនេះ។

**មន្ត្រីមានសមត្ថកិច្ច** សំដៅដល់ មន្ត្រីរាជការរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**នាយកដ្ឋានទទួលបន្ទុក** សំដៅដល់ នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**រដ្ឋមន្ត្រី** សំដៅដល់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: misti.smcabinet@gmail.com

**ប្រការ៥ ._**

រាល់ឧបករណ៍មាត្រាសាស្ត្រ អាចអនុញ្ញាតឱ្យនាំចូល សម្រាប់សកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម អាជីវកម្ម និង/ឬ វិស័យផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់ ស្តីពី មាត្រាសាស្ត្រ ត្រូវមានលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៦ ._**

រាល់ការនាំចូលឧបករណ៍មាត្រាសាស្ត្រ ត្រូវបំពេញបែបបទស្នើសុំ នៅការិយាល័យច្រកចេញ-ចូលតែមួយរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រៀងរាល់ម៉ោងនៃថ្ងៃធ្វើការ។

ឯកសារតម្រូវរួមមាន ៖

១. ពាក្យស្នើសុំ

២. សម្រង់ព័ត៌មាន ឬ រូបភាពនៃគំរូឧបករណ៍មាត្រាសាស្ត្រដែលត្រូវនាំចូល

៣. បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រដែលត្រូវនាំចូល។

**ប្រការ៧ ._**

លក្ខខណ្ឌនៃឧបករណ៍មាត្រាសាស្ត្រ ដែលត្រូវអនុញ្ញាតឱ្យនាំចូលគឺ ៖

- មានភាពត្រឹមត្រូវ និងសមមូល ឬស្របទៅតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចបានកំណត់ ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃច្បាប់ ស្តីពី មាត្រាសាស្ត្រ
- មានការបង្ហាញសមត្ថភាព អប្បបរមា និងអតិបរមា អំពីទម្ងន់ និង/ឬ រង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រនោះ និង/ឬពាណិជ្ជនាម ឬអាសយដ្ឋានផលិត។

**ប្រការ៨ ._**

ក្រោយពីមន្ត្រីមានសមត្ថកិច្ចនៃនាយកដ្ឋានទទួលបន្ទុក បានពិនិត្យវាយតម្លៃលើពាក្យស្នើសុំតាមបែបបទ និង នីតិវិធីដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះរួចរាល់ហើយ ក្រសួងត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួន ទៅអ្នកស្នើសុំក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលទទួលបានពាក្យស្នើសុំ។

ក្នុងករណីមិនយល់ព្រមតាមការស្នើសុំ ក្រសួងត្រូវឆ្លើយតបទៅអ្នកស្នើសុំ ដោយបញ្ជាក់ពីមូលហេតុឱ្យបានត្រឹមត្រូវ។

លិខិតអនុញ្ញាតនេះមានសុពលភាព ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខា។

**ប្រការ៩ ._**

រាល់ការផ្ទេរ ការលក់នូវលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ត្រូវមានការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ក្នុងករណីមានការពន្យាពេលនាំចូល អ្នកនាំចូលត្រូវធ្វើលិខិតស្នើសុំបន្តសុពលភាពជាលាយលក្ខណ៍អក្សរ មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន៣០ (សាមសិប) ថ្ងៃ មុនថ្ងៃផុតសុពលភាពនៃលិខិតអនុញ្ញាតនេះ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ១០ ..**

នៅពេលឧបករណ៍មាត្រាសាស្ត្រ បាននាំចូលមកដល់កម្ពុជា (ទីកន្លែងស្តុក) អ្នកនាំចូលត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកក្រសួង ដើម្បីស្នើសុំមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យអង្កេតជាក់ស្តែង។

**ប្រការ១១ ..**

ប្រកាសលេខ ៥១២ MIH / 2014 ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤ ស្តីពីនីតិវិធី និងបែបបទនៃការស្នើសុំនាំចូលឧបករណ៍មាត្រាសាស្ត្រ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ ..**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ គ្រប់អង្គភាពក្រោមឱវាទក្រសួង និងរូបវន្តបុគ្គល នីតិបុគ្គលដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

*« ដើម្បីជូនជ្រាប »*

- ដូចប្រការ១២
- ឯកសារ-កាលប្បវត្តិ




ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: msti.smcabinet@gmail.com